CDRI

Cambodia Development Resource Institute

សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា

# សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ លើកទី១៦

## យុទ្ធសាស្ត្រកំណើនថ្មីរបស់ប្រទេសកម្ពុជា៖ អាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់ និងនិរន្តរភាព

អត្ថបទនេះសង្ខេបនូវចំណុចសំខាន់ៗនៃការពិភាក្សាក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥។ សន្និសីទបានគូសបញ្ជាក់ពីតម្រូវការយុទ្ធសាស្ត្រកំណើនថ្មីរបស់ប្រទេសកម្ពុជា៖ ការវាយតម្លៃកំណើនរយៈពេលមធ្យម និងវែង សម្រាប់ការអភិវឌ្ឍប្រកបដោយភាពធន់ បរិយាបន្ន និងចីរភាព។




**“យុទ្ធសាស្ត្រ (កំណើនថ្មី) ផ្តោតលើតុល្យភាពរវាងល្បឿននៃកំណើនសេដ្ឋកិច្ច ទៅនឹងគុណភាពនៃកំណើន ជាជាងការផ្តោតតែលើកំណើនខ្ពស់។ មានន័យថា ទោះបីការកែទម្រង់រចនាសម្ព័ន្ធគ្រប់ជ្រុងជ្រោយអាចបណ្តាលឱ្យកំណើនសេដ្ឋកិច្ច មានកម្រិតទាបជាងកំណើនសក្តានុពលក្តី ក៏ចាំបាច់ត្រូវទទួលយក ដើម្បីជំរុញលើកកម្ពស់គុណភាព ចីរភាព និងបរិយាបន្ននៃកំណើនដែរ។”**

សុន្ទរកថាគន្លឹះរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ លើកទី១៦ រាជធានីភ្នំពេញ ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥

សន្និសីទប្រចាំឆ្នាំស្តីពីចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ លើកទី១៦ បានប្រមូលផ្តុំថ្នាក់ដឹកនាំ មកពីស្ថាប័នរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា ស្ថានទូតបរទេស ទីភ្នាក់ងារអង្គការសហប្រជាជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងស្ថាប័នអប់រំនានានៅក្នុងប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីមាគ៌ាកំណើនជាយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា ស្របពេលដែលមានភាពមិនច្បាស់លាស់ជាសកល។ ដោយផ្អែកលើរបាយការណ៍ពិសេសរបស់វិទ្យាស្ថាន CDRI ស្តីពី យុទ្ធសាស្ត្រកំណើនថ្មីរបស់កម្ពុជា សន្និសីទបានគូសបញ្ជាក់អំពីតម្រូវការនៃការផ្លាស់ប្តូរគោលនយោបាយ ដោយមានការផ្លាស់ប្តូរពីអត្រាកំណើនខ្ពស់ ទៅផ្តោតលើភាពធន់ បរិយាបន្ន និងភាពប្រកួតប្រជែងក្នុងរយៈពេលយូរអង្វែង។ សេចក្តីសង្ខេបចក្ខុវិស័យនេះ បង្ហាញពីការពិភាក្សាសំខាន់ៗដែលជាលទ្ធផលនៃសន្និសីទ ដោយរៀបរាប់យ៉ាងលម្អិតអំពីហានិភ័យនិងកាលានុវត្តភាពផ្នែកសេដ្ឋកិច្ច និងសកម្មភាពគោលនយោបាយបន្ទាន់ ដែលត្រូវការដើម្បីពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់ និងចីរភាព។

## កំណើនសេដ្ឋកិច្ចកម្ពុជា៖ សមិទ្ធផល និងបញ្ហាប្រឈមដែលកំពុងកើតមាន

ក្នុងរយៈពេលបីទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានផ្លាស់ប្តូរពីរបបសេដ្ឋកិច្ចកសិកម្មក្រោយសង្គ្រាម ទៅជាសេដ្ឋកិច្ចដែលមានកំណើនយ៉ាងឆាប់រហ័ស ជំរុញដោយវិស័យឧស្សាហកម្ម និងសេវាកម្ម។ នៅចន្លោះឆ្នាំ២០០០ និង ២០២២ ផលិតផលក្នុងស្រុកសរុប បានកើនឡើងជាមធ្យម៧% ក្នុងមួយឆ្នាំដែលបានជំរុញដោយវិនិយោគទុនបរទេស សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងឧស្សាហូបនីយកម្មយ៉ាងឆាប់រហ័ស។ បរិវត្តកម្មនេះបាននាំឱ្យប្រទេសកម្ពុជា សម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥។ ទោះជាយ៉ាងណាក៏ដោយបច្ចុប្បន្ននេះប្រទេសកម្ពុជាប្រឈមនឹងបញ្ហារាំងស្ទះរចនាសម្ព័ន្ធ ពោលគឺការពឹងផ្អែកខ្លាំងពេកលើកម្មន្តសាលដែលប្រើប្រាស់កម្លាំងពលកម្ម កំណើនផលិតភាពនៅទន់ខ្សោយ និងបញ្ហាជាប់គាំងស្ថាប័ន។ ជំងឺរាតត្បាតកូវីដ-១៩ ក៏បានបង្កើនភាពងាយរងគ្រោះនៅក្នុងវិស័យសំខាន់ៗមួយចំនួន។ តទៅមុខទៀត ប្រទេសកម្ពុជាត្រូវតែផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចដែលមានពិពិធកម្ម និងជំរុញដោយនវានុវត្តន៍ តាមការអនុវត្តកំណែទម្រង់យ៉ាងមុតស្រួច ដើម្បីបង្កើនភាពប្រកួតប្រជែង ពង្រឹងអភិបាលកិច្ច និងជំរុញកំណើនប្រកបដោយចីរភាព។

ជំហានសំខាន់មួយក្នុងការផ្លាស់ប្តូរនេះ គឺការពង្រឹងការចូលរួមរបស់វិស័យឯកជននៅក្នុងឧស្សាហកម្មដែលមានតម្លៃខ្ពស់ និងជំរុញដោយបច្ចេកវិទ្យា ជាពិសេសនៅក្នុងវិស័យកម្មន្តសាលកម្រិតខ្ពស់ និងសេដ្ឋកិច្ចបៃតង។ ការពិភាក្សានៅក្នុងអង្គសន្និសីទបានសង្កត់ធ្ងន់ថា ការផ្លាស់ប្តូរបែបនេះមានសារៈសំខាន់សម្រាប់ការធានាឱ្យទទួលបាននូវភាពធន់និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងទីផ្សារពិភពលោក។ ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរនេះ រាជរដ្ឋាភិបាល និងវិស័យឯកជន ត្រូវតែធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីធានាបាននូវការវិនិយោគដែលស្របនឹងអាទិភាពនៃការអភិវឌ្ឍជាតិ។

ការដោះស្រាយបញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានវិធីសាស្ត្រយ៉ាងមុតស្រួច ប៉ុន្តែក៏ត្រូវមានតុល្យភាពផងដែរ ពោលគឺវិធីសាស្ត្រដែលពន្លឿនការកែទម្រង់តាមវិស័យដែលត្រូវធ្វើភ្លាមៗ ទន្ទឹមគ្នានឹងការពង្រឹងមូលដ្ឋានគ្រឹះស្ថាប័ន ដើម្បីធានាដល់បរិវត្តកម្មយូរអង្វែង។ ផ្នែកខាងក្រោមនេះ បង្ហាញពីយុទ្ធសាស្ត្រពីរយ៉ាងរបស់កម្ពុជាសម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញ។

## តម្រូវការវិធីសាស្ត្រពីរយ៉ាង៖ កំណែទម្រង់វិស័យដែលមានភាពប្រកួតប្រជែងជាក់លាក់ និងកំណែទម្រង់គ្រប់ជ្រុងជ្រោយ

នៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ ការពិភាក្សាបានសង្កត់ធ្ងន់លើភាពចាំបាច់នៃយុទ្ធសាស្ត្រកំណើនផ្លូវពីរ ដោយធ្វើឱ្យមានតុល្យភាពនៃភាពប្រកួតប្រជែងនៃវិស័យសំខាន់ៗក្នុងរយៈពេលខ្លីទៅមធ្យម ដើម្បីពន្លឿនកំណើន ដោយចាប់ផ្តើមកំណែទម្រង់រចនាសម្ព័ន្ធភ្លាមៗ សម្រាប់ការផ្លាស់ប្តូររយៈពេលវែង និងធានាបានកំណើនប្រកបដោយភាពធន់ បរិយាបន្ន និងចីរភាព។ ការណ៍នេះទាមទារ៖

- **ការពន្លឿនកំណែទម្រង់តាមវិស័យ** សំដៅលើយុទ្ធសាស្ត្រឧស្សាហកម្មតាមគោលដៅ ផ្តោតលើការទាក់ទាញវិនិយោគទុនពីវិស័យឯកជនលើវិស័យដែលមានសក្តានុពលខ្ពស់ ដែលអាចជំរុញការធ្វើពិពិធកម្មការនាំចេញ ការបង្កើតការងារ និងបង្កើនផលិតភាព។
- **កំណែទម្រង់គ្រប់ជ្រុងជ្រោយ** សំដៅលើការដោះស្រាយភាពទន់ខ្សោយរបស់ស្ថាប័ន ឱនភាពមូលធនមនុស្ស និងបញ្ហាប្រឈមផ្នែកអភិបាលកិច្ច ដើម្បីទ្រទ្រង់បរិវត្តកម្ម និងនវានុវត្តន៍សេដ្ឋកិច្ចក្នុងរយៈពេលវែង។

អ្នកចូលរួមនៅក្នុងសន្និសីទបានសង្កត់ធ្ងន់ថា ការខកខានក្នុងការសម្រេចចិត្តលើវិធីសាស្ត្រទាំងពីរយ៉ាងខាងលើ នឹងប៉ះពាល់ដល់សក្តានុពលសេដ្ឋកិច្ច និងធ្វើឱ្យសមត្ថភាពដោះស្រាយការប៉ះទង្គិចពីខាងក្រៅរបស់កម្ពុជាចុះខ្សោយ រួមមានការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយ ការរំខានផ្នែកបច្ចេកវិទ្យា និងហានិភ័យទាក់ទងនឹងអាកាសធាតុ។ វិស័យឯកជនត្រូវតែដើរតួបុរេសកម្មបន្ថែមទៀតក្នុងការជម្នះឧបសគ្គទាំងនេះ ជាពិសេសតាមរយៈការគាំទ្រការអភិវឌ្ឍជំនាញ ការវិនិយោគលើបច្ចេកវិទ្យាទំនើប និងការជំរុញនវានុវត្តន៍នៅក្នុងទិដ្ឋភាពសេដ្ឋកិច្ចកម្ពុជាដែលកំពុងវិវត្ត។



ការជជែកដេញដោលគ្នាពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងការចូលរួមដ៏ទូលំទូលាយពីអ្នកចូលរួមជាកិត្តិយស បានសម្រួចអាទិភាពគោលនយោបាយដែលមាននៅក្នុងរបាយការណ៍ទិដ្ឋភាពទូទៅរបស់វិទ្យាស្ថាន CDRI ស្ដីពីយុទ្ធសាស្ត្រកំណើនថ្មីរបស់កម្ពុជា។ ទស្សនៈរួមលើសកម្មភាពគោលនយោបាយក្រោមយុទ្ធសាស្ត្រពីរយ៉ាង ត្រូវបានសង្ខេបដូចខាងក្រោម។

## ១. ការពន្លឿនកំណែទម្រង់តាមវិស័យ៖ ការជំរុញកំណើនរបស់កម្ពុជាក្នុងរយៈពេលខ្លីទៅមធ្យម

លទ្ធផលសន្និសីទបានលើកឡើងពីកាលានុវត្តភាពសំខាន់ៗសម្រាប់កម្ពុជា ក្នុងការសម្រេចបាននូវកំណើនមានគុណភាពខ្ពស់ តាមរយៈការវិនិយោគជាយុទ្ធសាស្ត្រក្នុងវិស័យមានសក្ដានុពលខ្ពស់ ដែលជំរុញឱ្យមានពិពិធកម្មឧស្សាហកម្ម បរិវត្តកម្មឌីជីថល និងអន្តរកាលបៃតង។ ការយល់ដឹងរួមគ្នាមួយបានលេចឡើងថា កំណែទម្រង់ទាំងនេះ ត្រូវតែអនុវត្តឱ្យបានឆាប់រហ័ស ដើម្បីជួយប្រទេសកម្ពុជាចាប់យកកាលានុវត្តភាពជាសកល ទន្ទឹមនឹងការជំរុញឱ្យមានភាពប្រកួតប្រជែងក្នុងស្រុក៖

### ១.១ កំណត់គោលដៅឡើងវិញនូវឧស្សាហកម្មដែលមានសក្ដានុពលខ្ពស់ដើម្បីភាពប្រកួតប្រជែងជាសកល

ភាពជោគជ័យនៃសេដ្ឋកិច្ចដែលមានកំណើនខ្ពស់នៅអាស៊ី ដូចជាវៀតណាម ថៃ និងម៉ាឡេស៊ី ត្រូវបានជំរុញដោយគោលនយោបាយឧស្សាហកម្មតាមវិស័យជាក់លាក់ ដែលទាក់ទាញវិនិយោគទុនជាយុទ្ធសាស្ត្រ និងអភិវឌ្ឍចង្កោមឧស្សាហកម្មឯកទេស។ ប្រទេសកម្ពុជាត្រូវតែប្រកាន់យកវិធីសាស្ត្រគោលដៅក្នុងការពង្រឹងមូលដ្ឋានឧស្សាហកម្មរបស់ខ្លួនដោយ៖

- ទាក់ទាញវិនិយោគិនបរទេសបង្គោល៖ កិច្ចពិភាក្សាបានសង្កត់ធ្ងន់ថា ប្រទេសកម្ពុជាត្រូវផ្ដោតលើវិនិយោគទុនពីសាជីវកម្មពហុជាតិសាសន៍ក្នុងវិស័យកែច្នៃកសិផល គ្រឿងអេឡិចត្រូនិក សេវាកម្មដែលអាចធ្វើពាណិជ្ជកម្ម និងទេសចរណ៍ ដើម្បីជំរុញចង្កោមឧស្សាហកម្ម និងការធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល។
- បង្កើនតំបន់សេដ្ឋកិច្ចពិសេស (SEZs) និងការលើកទឹកចិត្តដល់វិនិយោគទុន៖ អនុសាសន៍មួយដ៏ច្បាស់លាស់ គឺការរៀបចំយុទ្ធសាស្ត្រទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ រួមមានក្របខណ្ឌតំបន់សេដ្ឋកិច្ចពិសេសដែលបានកែសម្រួល ការលើកទឹកចិត្តខាងពន្ធលើការវិនិយោគ និងភាពជាដៃគូរវាងរដ្ឋនិងឯកជន គឺជាកត្តាចាំបាច់ ក្នុងការបង្កើនភាពទាក់ទាញរបស់កម្ពុជា ដើម្បីក្លាយជាមជ្ឈមណ្ឌលកម្មន្តសាល និងសេវាកម្ម។
- ដោះស្រាយបញ្ហាកកស្ទះផ្នែកបទប្បញ្ញត្តិ ហេដ្ឋារចនាសម្ព័ន្ធ និងជំនាញ៖ អ្នកចូលរួមបានគូសបញ្ជាក់ពីកង្វះកម្លាំងពលកម្មជំនាញ អប្រសិទ្ធភាពភស្តុភារកម្ម និងភាពស្មុគស្មាញនៃបទប្បញ្ញត្តិដែលជាឧបសគ្គចម្បងសម្រាប់ការពង្រីកឧស្សាហកម្ម។ ប្រទេសកម្ពុជាត្រូវតែចូលរួមធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន ដើម្បីបង្កើតកម្មវិធីបណ្ដុះបណ្ដាលកម្លាំងពលកម្មតាមវិស័យជាក់លាក់ សម្រួលនីតិវិធីវិនិយោគ និងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធខាងភស្តុភារកម្ម។

### ១.២ ការជំរុញអន្តរកាលបៃតងសម្រាប់កំណើនប្រកបដោយចីរភាព

អ្នកចូលរួមបានទទួលស្គាល់ជាទូទៅថា និរន្តរភាពជាភាពចាំបាច់នៃការប្រកួតប្រជែង។ ខ្សែច្រវាក់ផ្គត់ផ្គង់សកល កាន់តែមានការយល់ដឹងអំពីកាបូន ហើយវិនិយោគិនកំពុងផ្ដល់អាទិភាពដល់សេដ្ឋកិច្ចណាដែលប្ដេជ្ញាចិត្តចំពោះកំណើនបៃតង។ កម្ពុជាត្រូវតែប្រកាន់ជំហរយ៉ាងសកម្ម ជាអ្នកដឹកនាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។ ការពិភាក្សាក្នុងសន្និសីទបានឈានទៅដល់ចំណុចសកម្មភាពដូចខាងក្រោម៖

- ការពង្រីកយន្តការហិរញ្ញប្បទានបៃតង៖ រាជរដ្ឋាភិបាលត្រូវលើកកម្ពស់សញ្ញាបណ្ណបៃតង ការកំណត់តម្លៃកាបូន និងការលើកទឹកចិត្តខាងពន្ធដារសម្រាប់ក្រុមហ៊ុនដែលអនុវត្តដំណោះស្រាយថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យាឆ្លាតវៃខាងអាកាសធាតុ ។
- ការពង្រឹងឧស្សាហកម្មបៃតង៖ អ្នកចូលរួមបានឯកភាពលើតម្រូវការបន្ទាន់ ក្នុងការគាំទ្រការទទួលយកថាមពលស្អាត ដំណោះស្រាយប្រសិទ្ធភាពថាមពល និងបច្ចេកវិទ្យាចាប់យកកាបូន។ កម្ពុជាអាចទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសប្រកបដោយចីរភាព និងលើកកម្ពស់ភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់បៃតង។
- ការលើកទឹកចិត្តដល់កសិកម្មប្រកបដោយចីរភាព៖ វិស័យកសិកម្មត្រូវតែផ្លាស់ប្ដូរ ឆ្ពោះទៅរកការអនុវត្តកាបូនតិច និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ព្រមជាមួយនឹងការលើកទឹកចិត្តដល់កសិកម្មឆ្លាតវៃខាងអាកាសធាតុ ប្រព័ន្ធធារាសាស្ត្រប្រកបដោយចីរភាព និងគោលនយោបាយប្រើប្រាស់ដីប្រកបដោយការទទួលខុសត្រូវ។

### ១.៣ ការផ្តល់អាទិភាពដល់បរិយាបន្នកំណើនតាមរយៈឌីជីថលូបនីយកម្ម និងការគាំទ្រសហគ្រាសធុនតូច និងមធ្យម (SME)

សេដ្ឋកិច្ចឌីជីថលដ៏រឹងមាំ និងបរិយាកាសធុរកិច្ចប្រកបដោយបរិយាបន្ន គឺមានសារៈសំខាន់ណាស់សម្រាប់ការធ្វើឱ្យមានកំណើនដែលផ្អែកលើមូលដ្ឋានទូលំទូលាយ និងសេដ្ឋកិច្ចដែលមានភាពធន់។ ប្រទេសកម្ពុជាត្រូវតែផ្តល់អាទិភាពដល់ការពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការធ្វើទំនើបកម្មបទប្បញ្ញត្តិ ដើម្បីបង្កើនផលិតភាព និងការផ្សារភ្ជាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ទៅក្នុងទីផ្សារតំបន់ និងពិភពលោក។ សកម្មភាពគោលនយោបាយសំខាន់ៗមានដូចខាងក្រោម៖

- ការពន្លឿនបរិវត្តកម្មឌីជីថលដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ ក្នុងការផ្តល់សេវាសាធារណៈ៖ ដោយសារមានតម្រូវការអភិបាលកិច្ចអេឡិចត្រូនិចដែលបានកែលម្អ និងធ្វើបដិវត្តកម្ម ការចុះបញ្ជីពន្ធឌីជីថល និងនីតិវិធីគយដោយស្វ័យប្រវត្តិ ត្រូវបានគាំទ្រជាកត្តាជំរុញសក្តិសិទ្ធភាព តម្លាភាព និងទំនុកចិត្តរបស់វិនិយោគិន។
- ការពង្រីកការត្រៀមលក្ខណៈ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល នៅតាមតំបន់ជនបទ៖ ការពិភាក្សាបានគូសបញ្ជាក់ពីសារៈសំខាន់នៃការវិនិយោគគោលដៅក្នុងការពង្រីកអ៊ីនធឺណិត និងអក្ខរកម្មឌីជីថល ក្នុងការធ្វើឱ្យអាជីវកម្មនៅជនបទ កសិករខ្នាតតូច និងអ្នកចាប់ផ្តើមអាជីវកម្ម មានលទ្ធភាពទទួលបានទីផ្សារថ្មី និងសេវាកម្មហិរញ្ញវត្ថុ និងលើកកម្ពស់ផលិតភាព និងភាពប្រកួតប្រជែងរបស់ពួកគេ។
- ការលើកកម្ពស់បរិយាកាសបទប្បញ្ញត្តិធុរកិច្ច៖ ការធ្វើឱ្យបែបបទចុះបញ្ជីអាជីវកម្មមានលក្ខណៈងាយស្រួល ធានាការបង់ពន្ធដែលអាចព្យាករបាន និងការកែលម្អលទ្ធភាពទទួលបានហិរញ្ញវត្ថុសមរម្យ នឹងគាំទ្រដល់ការចុះបញ្ជីសហគ្រាសធុនមីក្រូ តូច និងមធ្យម ហើយអាចឱ្យពួកគេរីកចម្រើន និងធ្វើសមាហរណកម្មទៅក្នុងខ្សែច្រវាក់តម្លៃទូលំទូលាយជាងមុន។

## ២. កំណែទម្រង់គ្រប់ជ្រុងជ្រោយ៖ ការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់កំណើនរយៈពេលវែង

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ បានបញ្ជាក់ថា ខណៈពេលដែលមានការពន្លឿនកំណែទម្រង់តាមវិស័យ នឹងបង្កើតផលចំណេញក្នុងរយៈពេលខ្លីទៅមធ្យម ការណ៍នេះត្រូវតែបំពេញបន្ថែមដោយការផ្លាស់ប្តូររចនាសម្ព័ន្ធយ៉ាងស៊ីជម្រៅ ដើម្បីរក្សាកំណើនប្រកបដោយចីរភាពសម្រាប់វិបុលភាពរយៈពេលវែង។ បើគ្មានកំណែទម្រង់ជាមូលដ្ឋានទាំងនេះទេ កម្ពុជាប្រឈមនឹងការជាប់គាំងក្នុងអន្ទាក់ឋានៈជាប្រទេសចំណូលមធ្យម និងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ដែលប៉ះពាល់ដល់សេចក្តីប្រាថ្នាចង់ក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០របស់កម្ពុជា។

ដើម្បីកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់វិបុលភាពរយៈពេលវែង ចំណុចសំខាន់ៗពីសន្និសីទរួមមាន សារៈសំខាន់នៃក្របខ័ណ្ឌអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ការធ្វើទំនើបកម្មប្រព័ន្ធអប់រំនៅកម្ពុជា និងការបង្កើតបរិយាកាសធុរកិច្ចដែលគាំទ្រដល់នវានុវត្តន៍។ ប្រទេសកម្ពុជាត្រូវផ្តល់អាទិភាពចំពោះវិធានការកំណែទម្រង់សំខាន់ៗដូចខាងក្រោម។

### ២.១ ការកែលម្អស្ថាប័ន និងអភិបាលកិច្ចជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍរយៈពេលវែង

ប្រព័ន្ធអភិបាលកិច្ចដែលដំណើរការល្អ ត្រូវបានកំណត់ថាជាកត្តាចាំបាច់សម្រាប់ការរក្សាទំនុកចិត្តវិនិយោគិន ដែលធានាស្ថិរភាពបទប្បញ្ញត្តិ និងការកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយ កម្ពុជានៅតែបន្តប្រឈមនឹងបញ្ហាប្រសិទ្ធភាពរដ្ឋបាលសាធារណៈ ការអនុវត្តច្បាប់ និងភាពព្យាករបាននៃគោលនយោបាយសារពើពន្ធ ដែលធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងធុរកិច្ច និងទំនុកចិត្តសាធារណៈ។

ដើម្បីកែលម្អអភិបាលកិច្ច ប្រទេសកម្ពុជាត្រូវ៖

- អនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ និងប្រព័ន្ធច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយ៖ មតិឯកភាពមួយលើកឡើងពីតម្រូវការនៃការធ្វើទំនើបកម្មនីតិវិធីរដ្ឋបាល ការពង្រឹងការអនុវត្តច្បាប់ និងឯករាជ្យភាពរបស់តុលាការ ដើម្បីបង្កើនតម្លាភាព សក្តិសិទ្ធភាព និងទំនុកចិត្តវិនិយោគិន។
- ពង្រឹងការសម្របសម្រួលរវាងស្ថាប័នរដ្ឋ តាមរយៈការធ្វើសេចក្តីសម្រេចចិត្តដែលផ្អែកលើទិន្នន័យ៖ ការអនុម័តគោលនយោបាយ និងយន្តការទិន្នន័យបើកចំហ និងការបញ្ជាក់ពីទំនួលខុសត្រូវស្ថាប័ននីមួយៗ មានសារៈសំខាន់ក្នុងការជំរុញការតាក់តែងគោលនយោបាយដែលមានភាពប្រទាក់ក្រឡា និងផ្អែកលើភស្តុតាង នៅគ្រប់ក្រសួង និងស្ថាប័នផ្សេងៗ។

- អភិវឌ្ឍ និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថលសាធារណៈ៖ ការបង្កើតប្រព័ន្ធអេកូឡូស៊ីអភិបាលកិច្ចឌីជីថលប្រកបដោយភាពធន់ និងមានបរិយាបន្ន តាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន វិធានការសន្តិសុខតាមអ៊ីនធឺណិតដ៏រឹងមាំ និងក្របខ័ណ្ឌបទប្បញ្ញត្តិចាំបាច់ ដើម្បីបង្កើនលទ្ធភាពទទួលបាន ប្រសិទ្ធភាព តម្លាភាព សម្រាប់នវានុវត្តន៍ប្រកបដោយក្រមសីលធម៌ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។
- បង្កើនតម្លាភាព និងភាពព្យាករបាននៃប្រព័ន្ធពន្ធដារ៖ ការបង្កើនតម្លាភាព និងភាពព្យាករបាននៃពន្ធដារ នឹងពង្រឹងទំនុកចិត្តវិនិយោគិន ជំរុញការអនុលោមតាមច្បាប់ និងធានាការបង្កើតប្រាក់ចំណូលក្នុងស្រុកប្រកបដោយចីរភាព នោះវាអាចកាត់បន្ថយការពឹងផ្អែករបស់កម្ពុជាលើការផ្តល់មូលនិធិខាងក្រៅ។
- បញ្ជូនអ្នកជំនាញបច្ចេកទេសទៅកាន់តំបន់ជនបទ៖ ការដោះស្រាយវិសមភាពនៅក្នុងតំបន់លើផ្នែកឱកាសសេដ្ឋកិច្ចនានា និងការទទួលបានសេវាសាធារណៈ គឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន។ ការបញ្ជូនអ្នកជំនាញឯកទេសទៅតាមតំបន់ជនបទ អាចជួយសម្រួលដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការទទួលបានសេវាសាធារណៈប្រកបដោយសមធម៌។

### ២.២ ការកសាងមូលធនមនុស្ស ដើម្បីទ្រទ្រង់វឌ្ឍនភាពសេដ្ឋកិច្ច

កម្លាំងពលកម្មដែលអាចសម្របខ្លួន និងមានផលិតភាព គឺជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចទំនើបដែលមានកំណើនខ្ពស់។ ដោយសារប្រទេសកម្ពុជាកំពុងឈានឆ្ពោះទៅរកឧស្សាហកម្មដែលមានតម្លៃខ្ពស់ ប្រទេសកម្ពុជាត្រូវតែធ្វើកំណែទម្រង់រចនាសម្ព័ន្ធវិស័យអប់រំ និងទីផ្សារការងាររបច្ចុប្បន្នរបស់ខ្លួន ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ចថ្មីៗ។ ការខកខានក្នុងការធ្វើកំណែទម្រង់ទាំងនេះ នឹងនាំឱ្យមានបញ្ហានៃភាពមិនស៊ីសង្វាក់គ្នានៃជំនាញ ការថយចុះសមត្ថភាពប្រកួតប្រជែង និងការបង្កើនជំនាញរបស់កម្មករដែលមានកម្រិត។

ដើម្បីពង្រឹងមូលធនមនុស្ស ប្រទេសកម្ពុជាត្រូវ៖

- កែទម្រង់ស៊ីជម្រៅក្នុងប្រព័ន្ធអប់រំ ចាប់ពីមត្តេយ្យសិក្សា ដល់ឧត្តមសិក្សា៖ ការអំពាវនាវមួយបានធ្វើឡើងដើម្បីឱ្យប្រព័ន្ធអប់រំផ្តោតលើគណនេយ្យភាព ការកែលម្អគុណភាព និងការតម្រឹមកម្លាំងពលកម្ម។ ការលើកកម្ពស់ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអភិវឌ្ឍជំនាញទន់ នឹងមានសារៈសំខាន់ក្នុងការឱ្យកម្មករត្រៀមខ្លួនជាស្រេច សម្រាប់ឧស្សាហកម្មដែលជំរុញដោយបច្ចេកវិទ្យា និងសេដ្ឋកិច្ចដែលផ្អែកលើចំណេះដឹង។
- ពង្រីកកម្មវិធីគាំពារសង្គម និងដាក់ចេញគោលនយោបាយគ្រួសារមេត្រី៖ ការពង្រឹងការគាំពារពលកម្ម ការទ្រទ្រង់ការថែទាំកុមារ និងសន្តិសុខនៅកន្លែងធ្វើការ នឹងបង្កើនការចូលរួមក្នុងកម្លាំងពលកម្ម និងបង្កើតបរិយាកាសសេដ្ឋកិច្ចដែលមានស្ថិរភាពជាងមុន ដល់កម្មករ និងអាជីវកម្មខ្នាតតូច។
- ធានាលទ្ធភាពទទួលបានសេវាថែទាំសុខភាពជាសកលនិងប្រកបដោយគុណភាព៖ អ្នកចូលរួមបានសង្កត់ធ្ងន់ថា ការកែលម្អហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពសាធារណៈ ការពង្រីកដៃនគ្របដណ្តប់ផ្នែកវេជ្ជសាស្ត្រ និងការដោះស្រាយវិសមភាពតាមតំបន់សេវាថែទាំសុខភាព គឺមានសារៈសំខាន់ណាស់សម្រាប់ទ្រទ្រង់ផលិតភាពនៃកម្លាំងពលកម្ម និងសុខុមាលភាពរយៈពេលវែង។

ប្រទេសកម្ពុជាកំពុងឈរនៅលើផ្លូវបំបែកដ៏សំខាន់មួយ។ ប្រសិនបើគ្មានសកម្មភាពជាក់លាក់ទេ ប្រទេសកម្ពុជាអាចប្រឈមនឹងហានិភ័យក្នុងការបាត់បង់ភាពប្រកួតប្រជែងរបស់ខ្លួន នៅក្នុងសេដ្ឋកិច្ចសកលដែលកាន់តែស្មុគស្មាញ។ វិធីសាស្ត្រពីរយ៉ាងដែលបានរៀបរាប់នៅក្នុងសេចក្តីសង្ខេបចក្ខុវិស័យនេះ ផ្តល់នូវផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ ក្នុងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់ និងចីរភាព។ តាមរយៈការផ្តល់អាទិភាពដល់កំណែទម្រង់តាមវិស័យគោលដៅ ស្របពេលនឹងការដោះស្រាយឧបសគ្គរចនាសម្ព័ន្ធជាមូលដ្ឋានគ្រឹះ ប្រទេសកម្ពុជាអាចធានាបាននូវសេដ្ឋកិច្ចដែលមានភាពធន់ ភាពប្រកួតប្រជែង និងមានចំណូលខ្ពស់។

## តួនាទីរបស់វិទ្យាស្ថាន CDRI ក្នុងការគាំទ្រចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា

ខណៈដែលប្រទេសកម្ពុជាបន្តនូវចក្ខុវិស័យអភិវឌ្ឍន៍ប្រកបដោយគុណភាពខ្ពស់ និងចីរភាព ការតាក់តែងគោលនយោបាយដែលផ្អែកលើភស្តុតាង នឹងក្លាយជាចំណុចសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍដ៏ស្មុគស្មាញរបស់កម្ពុជា។ ស្របតាមផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ (២០២៥-២០៣០) វិទ្យាស្ថាន CDRI នឹងបន្តដើរតួនាទីជាវិទ្យាស្ថានអភិវឌ្ឍន៍ចំណេះដឹងឈានមុខគេ ដែលជំរុញដំណោះស្រាយគោលនយោបាយមើលឆ្ពោះទៅមុខ គាំទ្រការកសាងសមត្ថភាពអ្នកដឹកនាំជំនាន់ថ្មី និងរៀបចំការពិភាក្សាដែលទូលំទូលាយលើបញ្ហាប្រឈមខាងគោលនយោបាយសំខាន់ៗ។

ផ្អែកលើការយល់ដឹងស៊ីជម្រៅដែលបានចែករំលែកនៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ វិទ្យាស្ថាន CDRI នឹងផ្ដោតលើអាទិភាពជាយុទ្ធសាស្ត្រចំនួនបួន ដើម្បីគាំទ្រដល់បរិវត្តកម្មសេដ្ឋកិច្ចកម្ពុជា៖

- **កំណត់ទិសដៅនៃការពិភាក្សាអំពីការអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់កម្ពុជា៖** ការផ្ដល់នូវទស្សនៈស៊ីជម្រៅដែលមានសង្គតភាព ទាន់ពេលវេលា ផ្អែកលើទិន្នន័យគ្រប់គ្រាន់ ដើម្បីផ្ដល់ជាធាតុចូលដល់យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយដោះស្រាយបញ្ហា ទន្ទឹមគ្នានឹងការបង្កើតវេទិកាពិភាក្សាប្រកបដោយបរិយាបន្នសម្រាប់ភាគីពាក់ព័ន្ធនានា។
- **ការផ្ដល់ទិន្នន័យ និងការវិភាគច្បាស់លាស់៖** ការផ្ដល់នូវទិន្នន័យទូលំទូលាយ និងទាន់ពេលវេលា ទាំងទិន្នន័យម៉ាក្រូ និងមីក្រូ បែបបរិមាណវិស័យ និងគុណភាពវិស័យ តាមរយៈការប្រមូល និងវិភាគទិន្នន័យជាទៀងទាត់ និងឯករាជ្យ។ ហេតុនេះវានឹងគាំទ្រដល់ដំណើរការត្រួតពិនិត្យ និងវាយតម្លៃ រួមចំណែកដល់ការអភិវឌ្ឍមូលដ្ឋានទិន្នន័យស្របគ្នា និងជួយបង្កើតសូចនាករដ៏រឹងមាំដើម្បីកែលម្អសមិទ្ធកម្ម។
- **ការពង្រឹងសមត្ថភាពបុគ្គល និងស្ថាប័ន៖** ការពង្រឹងជំនាញស្រាវជ្រាវ និងសមត្ថភាពអ្នកដឹកនាំជំនាន់ថ្មីដែលកំពុងរីកចម្រើនក្នុងវិស័យសាធារណៈ និងដៃគូអភិវឌ្ឍន៍ តាមរយៈគំនិតផ្ដួចផ្ដើមកសាងសមត្ថភាពចំគោលដៅ ធានាឱ្យមានការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍កាន់តែមានប្រសិទ្ធភាព និងសក្ដិសិទ្ធភាព។
- **ការលើកកម្ពស់ការរៀនសូត្រ និងកិច្ចសហប្រតិបត្តិការអន្តរតំបន់៖** ដោយផ្អែកលើបណ្ដាញរយៈពេលវែងរបស់វិទ្យាស្ថាន CDRI ជាមួយស្ថាប័នស្រាវជ្រាវ និងដៃគូក្នុងតំបន់ គំនិតផ្ដួចផ្ដើមនេះនឹងផ្លាស់ប្ដូរបណ្ដាញនេះជាប្រព័ន្ធឱ្យទៅជាមជ្ឈមណ្ឌលសម្រាប់អ្នកស្រាវជ្រាវថ្មីនិងអ្នកដែលមានពិសោធន៍ ដើម្បីចែករំលែក រៀនសូត្រ និងសហរចនាអនុសាសន៍គោលនយោបាយប្រាកដនិយមលើបញ្ហាប្រឈមនៃការអភិវឌ្ឍសំខាន់ៗ។

តាមរយៈការស្រាវជ្រាវយ៉ាងម៉ត់ចត់ ការចូលរួមគោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព វិទ្យាស្ថាន CDRI នឹងបន្តដើរតួនាទីសំខាន់ក្នុងការរៀបចំមាគ៌ារបស់ប្រទេសកម្ពុជា ឆ្ពោះទៅរកសេដ្ឋកិច្ចមានប្រាក់ចំណូលខ្ពស់និងប្រកបដោយភាពធន់ ភាពប្រកួតប្រជែង និងបរិយាបន្ន។

*ដើម្បីស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅអំពីការពិភាក្សា និងអនុសាសន៍គោលនយោបាយ ដែលកំណត់ក្របខ័ណ្ឌនៃសន្និសីទនេះ អ្នកអាននិងអ្នកចូលរួមជាកិត្តិយសទាំងអស់ អាចចូលមើលបន្ថែមក្នុង* ***របាយការណ៍ទិដ្ឋភាពទូទៅ*** *និង* ***ឯកសារសាវតារ*** *ដែលផ្ដល់ការវិភាគស៊ីជម្រៅលើកំណែទម្រង់តាមវិស័យ ភាពធន់នៃសេដ្ឋកិច្ច និងបរិវត្តកម្មឌីជីថល។*




























**សូមស្កេននៅទីនេះ**
**ដើម្បីរកឯកសារទាំងនេះ**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)**
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក
ប្រអប់សំបុត្រលេខ ៦៦២ ភ្នំពេញ កម្ពុជា
+855 23 881 701/881 916/883 603
អ៊ីម៉ែល: cdri@cdri.org.kh | www.cdri.org.kh

រៀបចំដោយ

CDRI
Cambodia Development Resource Institute

ក្នុងភាពជាដៃគូជាមួយ

Australian Aid

CAPRED